ព្រឹត្តិបត្រផ្សព្វផ្សាយកសិកម្ម AGRICULTURAL EXTENSION BULLETIN
លេខទី ០១ ត្រីមាសទី១ ឆ្នាំ ២០១៨ ចេញផ្សាយដោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម A PUBLICATION OF THE DEPARTMENT OF AGRICULTURAL EXTENSION
Facebook : នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម / Department of Agricultural Extension



# បទពិសោធន៍ចិញ្ចឹមមាន់ភ្ញាស់កូន

## កសិករជ័យលាភី ពុត សុជា ភូមិត្រពាំងសង្កែ ឃុំស្រឡប់ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ

ព្រឹត្តប័ត្រព័ត៌មានកសិកម្មនេះ រៀបចំឡើងក្នុងគោលបំណងចងក្រង នូវរាល់បទពិសោធន៍ជោគជ័យផ្សេងៗ ដែលជាស្នាដៃអនុវត្តផ្ទាល់ របស់កសិករឆ្នើមទទួលជ័យលាភីប្រចាំឆ្នាំ ដែលបានឆ្លងកាត់ការប្រឡង និងវាយតម្លៃយ៉ាងសុក្រិត ពីគណៈកម្មការជំនាញ ពាក់ព័ន្ធនឹងវិស័យកសិកម្ម ដើម្បីធ្វើការផ្សព្វផ្សាយបន្តឱ្យបានទូលំទូលាយ ដល់បងប្អូនកសិករនៅតំបន់ជនបទ ដែលមានជីវភាពរស់នៅ ពឹងផ្អែកលើវិស័យកសិកម្មជាចម្បង។ ក្នុងព្រឹត្តិប័ត្រនេះដែរ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម បានលើកយកបទពិសោធន៍ជោគជ័យរបស់ លោកស្រី ពុត សុជា ជាកសិករជ័យលាភី រស់នៅភូមិត្រពាំងសង្កែ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ លើការងារចិញ្ចឹមមាន់ភ្ញាស់កូន មកបង្ហាញជូនដូចខាងក្រោម៖

### ១- អំពីប្រវត្តិ

លោកស្រី ពុត សុជា បានរៀបរាប់ពីប្រវត្តិ និងបទពិសោធន៍ក្នុងការចិញ្ចឹមមាន់ភ្ញាស់កូនរបស់គាត់ថាៈ ការចិញ្ចឹមមាន់របស់គាត់ផ្តើមពីការចិញ្ចឹមមាន់មេ១០ក្បាល មាន់ឈ្មោល ០២ក្បាល បន្ទាប់ពីបានរស់ជាមួយគ្នាជាប្តី ប្រពន្ធជាមួយលោក ថៃ សុខហ៊ាង នាឆ្នាំ២០០៤ មកដល់ឆ្នាំ២០១៨ លោកស្រីបានពង្រីកការចិញ្ចឹមមាន់ ដោយបានរៀបចំទ្រុងទៅតាមបទដ្ឋានបច្ចេកទេស បំពាក់ទូភ្ញាស់ពាក់កណ្តាលស្វ័យប្រវត្តិ និងមានមាន់មេពូជ១៨០ក្បាល មាន់ឈ្មោល ៣០ក្បាល រកចំណូលលើសពី ២,០០០,០០០រៀលក្នុងមួយខែៗ បន្ទាប់ពី គម្រោងសន្តិសុខស្បៀងសម្រាប់កសិករក្រីក្រ បានផ្តល់ជូនលោកស្រី ពុត សុជា នូវទ្រុងពូជមាន់ និងការបណ្តុះបណ្តាលពីការចិញ្ចឹមថែរក្សា ការកែច្នៃផ្សំចំណី វិធានការការពារ និងការគ្រប់គ្រងអាជីវកម្មចិញ្ចឹមមាន់។

### ២- អំពីការជ្រើសរើសទីតាំង

លោកស្រី បានមានប្រសាសន៍ថា ការជ្រើសរើសទីតាំងសម្រាប់ការចិញ្ចឹមមាន់ ត្រូវតែធានាបាននូវសុវត្ថិភាព គុណភាព បរិស្ថានសម្រាប់ទាំងមនុស្ស សត្វ និងរុក្ខជាតិ ដូចជាថាទ្រុងមាន់ត្រូវស្ថិតនៅដាច់ពីផ្ទះ និងឃ្លាតពីរបងព្រំដី ជុំវិញទ្រុងមាន់ ត្រូវមានដើមឈើសម្រាប់ជាម្លប់ ផ្តល់នូវអុកស៊ីសែនសមល្មម និងកាត់បន្ថយក្លិន និងជាពិសេសទីតាំងទ្រុងមាន់មិនលិចទឹក មិនជាំទឹកដោយសារទឹកភ្លៀងនោះទេ។



### ៣- ការរៀបចំទ្រុងមាន់

លោកស្រី ពុត សុជា បានរៀបរាបប្រាប់ថាការរៀបចំទ្រុងមាន់ត្រូវធ្វើយ៉ាងណាឱ្យធានានូវផាសុខភាពមាន់និងអាចប្រើប្រាស់បានយូរអង្វែង ដូចជា យើងអាចសាងសង់អំពីដែកទាំងសរសរ ជញ្ជាំងបន្ទប់មាន់ និងដំបូលប្រក់សង្កសីពណ៌ទឹកប្រាក់ រៀបឥដ្ឋបាតទ្រុងកម្ពស់ ៣០-៤០ស.ម ឱ្យផុតពីដីដែល

មានសរសរជើងរៀងកម្ពស់ ២,២ ម និង សរសរក្រឡោងកម្ពស់ ៣ម៉ែត្រ បែងចែងបន្ទប់ជា ២ជួរ ទល់ខ្នងគ្នា មានទំហំ ២ម x ២ម ។ បន្ទប់នីមួយៗមានធ្នើរសម្រាប់មាន់ឡើងដេក និងក្រាបពង កម្ពស់ប្រមាណ ១ម ពីបាតទ្រុង។ មួយប្រអប់ដាក់មាន់មេ ៦ក្បាល និងមាន់ឈ្មោល ១ក្បាលទីធ្លាសម្រាប់មាន់ចេញលេងតភ្ជាប់ពីបន្ទប់នីមួយៗ ទំហំ២ម x ៤ម ដោយប្រើប្រាស់សំណាញ់ជ័រ តពីជើងរៀង ជាបន្ទះឫស្សី មានកម្ពស់ ២៥ស.ម បាតទ្រុងចាក់សាប និងក្រាលអង្កាមពីលើ រៀបចំប្រព័ន្ធទុយោតំណក់ទឹក សម្រាប់មាន់ផឹកនិងជាពិសេសរៀបចំសួនបន្លែ សម្រាប់ជាសមាសធាតុផ្សំជាចំណីមាន់។



## ៤- ការជ្រើសរើសពូជមាន់

លោកស្រី ពុត សុជា បានរៀបរាប់ប្រាប់ផងដែរថា ចំពោះការជ្រើសរើសពូជមាន ត្រូវជ្រើសរើស ទាំងមាន់មេ និងមាន់ឈ្មោល ត្រូវមានមាឌធំ សុខភាពល្អ រហ័សរហួន មិនធ្លាប់មានជំងឺ មិនជាន់ឈាម មានជើងពណ៌លឿង និង បើមាន់ឈ្មោលត្រូវពូកែជាន់ម បើមាន់មេជាមាន់ដែលអាចផ្តល់ស៊ុតច្រើន។



## ៥- ចំណីមាន់

លោកស្រី ពុត សុជា បានប្រាប់ឱ្យដឹងទៀតថាការផ្តល់ចំណីមាន់មិនដូចគ្នាទេ ទាំងបរិមាណ ទាំងគុណភាពគឺត្រូវគិតទៅតាមប្រភេទរបស់មាន់ ដូចជាថា កូនមាន់អាយុពី ១ថ្ងៃទៅ២១ថ្ងៃ ក្នុងរយៈកាលនេះយើងប្រើចំណីផ្សំស្រេចពីក្រុមហ៊ុនផលិតផលចំណីតែម្តង។ បើជាមេមាន់កំពុងពងនិងមាន់បា ត្រូវផ្តល់ចំណី ដែលមានសមាសភាព ដូចជា កន្ទក់ ២០% ពោតក្រហម ៤០% អំបិល ០,៣% ចុងអង្ករ ១០% មេចំណី ១៥% ម្សៅប្រេមិច ០.៥% ម្សៅដំឡូងមី ១០% ម្សៅសំបកខ្យង ៥% កាកសំណល់ផ្ទះបាយ និងបន្លែបៃតងផងដែរ និងបើជាមាន់សាច់ ត្រូវផ្តល់ចំណីដែលមានសមាសភាពដូចជាកន្ទក់ ២០% ពោតក្រហម ៣០% អំបិល០,៣% ចុងអង្ករ ១០% មេចំណី ២០% ម្សៅប្រេមិច ០.៥% ម្សៅដំឡូងមី ២០% និងលាយជាមួយបន្លែបៃតងដូចមាន់មេដែរ។





## ៦- ការផ្តល់ចំណី

លោកស្រី ពុត សុជា បានរៀបរាប់ប្រាប់ថាការផ្តល់ចំណីក៏ត្រូវគិតទៅតាមវ័យរបស់មាន់ដែរដូចជា បើជាកូនមាន់អាយុពី១ថ្ងៃទៅ២១ថ្ងៃ យើងត្រូវផ្តល់ចំណីមួយថ្ងៃបួនដង

ព្រឹកពីរដងល្ងាចពីរដងដោយប្រើចំណីផ្សំស្រេចក្នុងបរិមាណ ១២ គីឡូក្រាម សម្រាប់មាន់ ១០០ក្បាល ក្នុងរយៈពេល២១ ថ្ងៃ។ តែបើជាមេមាន់កំពុងពង និងមាន់បាយើងត្រូវផ្តល់ចំណីមួយថ្ងៃពីរដងគឺ ព្រឹក និងល្ងាច ដោយប្រើចំណីផ្សំ ១០គ.ក្រ ផ្សំបន្លែបៃតង ៥គីឡូក្រាម ក្នុង១ថ្ងៃ សម្រាប់មាន់១០០ក្បាល និងបើជាមាន់សាច់អាយុចាប់ពីមួយខែដល់លក់យើងត្រូវផ្តល់ចំណីមួយថ្ងៃពីរដងគឺ ព្រឹក និងល្ងាចដោយប្រើចំណីផ្សំ ៦ គីឡូក្រាម ផ្សំបន្លែបៃតង ៤គីឡូក្រាមក្នុង១ថ្ងៃ សម្រាប់មាន់ ១០០ក្បាល។



## ៦- ការផ្តល់ទឹក

លោកស្រី ពុត សុជា បានរៀបរាប់ប្រាប់បន្តទៀតថាទឹកមានសារៈសំខាន់ណាស់ ក្នុងការចិញ្ចឹមមាន់ ទឹកសម្រាប់មាន់ផឹកត្រូវតែស្អាត ប្រព័ន្ធតំណក់ទឹក សម្រាប់មាន់ជំទង់ និងមាន់មេ បា ងាយផ្សំសារធាតុថ្នាំរុក្ខជាតិ ដាក់បញ្ចូលដើម្បីឱ្យមាន់ផឹកធ្វើឱ្យមាន់មានសុខភាពល្អ ការពារ ព្យាបាលជំងឺ និងធ្វើឱ្យមាន់ឆាប់ធំធាត់។

## ៧- របៀបភ្ញាស់ស៊ុតមាន់

លោកស្រី ពុត សុជា បានរៀបរាប់បន្តទៀតថាការភ្ញាស់ស៊ុតមាន់ដោយម៉ាស៊ីនភ្ញាស់ ពាក់កណ្តាលស្វ័យប្រវត្តិ ត្រូវអនុវត្តតាមជំហានដូចជាត្រូវរើស និងសន្សំស៊ុតមាន់ រក្សាទុកនៅកន្លែងត្រជាក់ មានខ្យល់អាកាសល្អរយៈពេល ៣-៦ ថ្ងៃ រួចទើបយកទៅរៀបចំដាក់ក្នុងទូភ្ញាស់ ពេលដាក់ក្នុងទូរួចហើយចាប់ពីថ្ងៃទី១ដល់ថ្ងៃទី១៧ ត្រូវរក្សាសីតុណ្ហភាពក្នុងទូ ត្រឹម ៣៧,៥អង្សាសេ និងសំណើម ៦០-៦៥%រយៈពេល ១០ថ្ងៃ ត្រូវពិនិត្យមើលការបង្កកំណើតរបស់ស៊ុត។ បើមិនបង្កកំណើតទេ យកចេញហើយចាប់ពីថ្ងៃទី១៨ ដល់ថ្ងៃទី១៩ ឈប់បង្វិលស៊ុត និងបន្ថយកម្តៅមកនៅ ៣៧,៥ អង្សាសេ តែសំណើមត្រូវបង្កើនដល់ ៧០% ស៊ុតមាន់នឹងញាស់នៅថ្ងៃទី២០ ឬ ២១។



## ៨- របៀបថែរក្សាកូនមាន់

លោកស្រី ពុត សុជា បានរៀបរាប់ប្រាប់ថា កូនមាន់ពេលយកចេញពីទូភ្ញាស់ ត្រូវរក្សាទុកក្នុងទ្រុងកម្តៅកូនមាន់ដោយអំពូលភ្លើង រយៈពេល៧-១០ថ្ងៃ ដោយ កូនមាន់អាយុពី២-៤ថ្ងៃ ផ្តល់ថ្នាំវីតាមីន និងអាម៉កស៊ីលីន កូនមាន់អាយុ ៥-៦ថ្ងៃ ត្រូវបណ្តក់វ៉ាក់សាំងការពារជំងឺញូវកាស កូនមាន់អាយុ ៨-១០ ថ្ងៃ ផ្តល់ថ្នាំអ៊ែនរ៉ូផ្លុកហ្សាស៊ីន និងវីតាមីនកូនមាន់អាយុ ១១-១៣ថ្ងៃ ត្រូវជួសស្លាបការពារជំងឺអុត កូនមាន់អាយុ ១៤-១៦ថ្ងៃ ផ្តល់ថ្នាំអំពីស៊ីន និងកូនមាន់អាយុ ២១ថ្ងៃ ត្រូវបណ្តក់វ៉ាក់សាំងការពារជំងឺញូវកាសម្តងទៀត និងអាចលក់សម្រាប់យកទៅចិញ្ចឹមបាន។



## ៩- របៀបថែរក្សាមាន់សាច់

លោកស្រី ពុត សុជា បានរៀបរាប់ប្រាប់បន្ថែមទៀតថា ចាប់ពីមាន់អាយុបាន ២២ថ្ងៃ អាចយកមកដាក់ចិញ្ចឹមក្នុងទ្រុងបំប៉នយកសាច់ដោយផ្តល់ចំណីមាន់ ២-៣ដង/ថ្ងៃ ពេលមាន់អាយុ ៤០-៤៥ថ្ងៃ ត្រូវទម្លាក់ព្រួនរៀងរាល់៣ខែម្តង ចំពោះមាន់បន្តពូជ និងពេលមាន់អាយុ ៦០ថ្ងៃ ត្រូវចាក់វ៉ាក់សាំងការពារជំងឺអាសន្នរោគ និងចុងក្រោយពេលមាន់អាយុ៤ខែ នឹងមានទម្ងន់ ១,២-១,៤ គ.ក្រ/ក្បាល អាចរើសទុកធ្វើពូជបន្ត និងសល់ប៉ុន្មានលក់ចេញជាមាន់សាច់។



## ១០- វិធានការណ៍ការពារជំងឺឆ្លងមាន់

លោកស្រី ពុត សុជា បានរៀបរាប់ប្រាប់ថាទ្រុងមាន់ត្រូវមានរបងសុវត្ថិភាព ហើយរៀបចំបន្ទប់មាន់ដាច់ដោយឡែកពីគ្នា ធុងទឹក ស្នូកចំណី ទ្រុងកូនមាន់ ត្រូវសម្អាត និងហាលថ្ងៃទីធ្លាចិញ្ចឹមមាន់ ត្រូវបាចកំបោរសម្លាប់មេរោគជាប្រចាំការចេញចូលត្រូវជាន់កំបោរសម្លាប់មេរោគជាមុន ត្រូវផ្តល់ទឹកដែលត្រាំពីរុក្ខជាតិដូចជា ស្លៅ វល្លិ៍ ពេជ្រ គល់ស្លឹកគ្រៃ ៥-៦ដង/ខែ និងមាន់ងាប់ដោយសារជំងឺ ត្រូវតែកប់ចោល។



## ១១- ការទុកដាក់ និងប្រើប្រាស់លាមកមាន់

លោកស្រី ពុត សុជា បានរៀបរាប់ប្រាប់ផងដែរថា ទ្រុងមាន់សាច់ ត្រូវប្រមូលអង្កាម និងលាមកមាន់ ១០ថ្ងៃម្តង ចំណែកទ្រុងមាន់ មេពង ត្រូវប្រមូល១ខែម្តង យកទៅរក្សាទុកលាយផ្សំធ្វើជីកំប៉ុស្ត សម្រាប់ដាក់ដំណាំ។



## ១២- បុព្វហេតុជោគជ័យ និងការចែករំលែកបទពិសោធន៍

មកដល់ចំណុចចុងក្រោយនេះលោកស្រី ពុត សុជា បានរៀបរាប់ថា បុព្វហេតុដែលបណ្តាលឱ្យលោកស្រីជោគជ័យ ក៏ព្រោះតែលោកស្រីបានអនុវត្តតាមបច្ចេកទេស និងការណែនាំពីមន្ត្រីជំនាញរបស់គម្រោង និងបានសិក្សានូវបទពិសោធន៍ពីអ្នកចិញ្ចឹមមុនៗ ដែលទទួលបានជោគជ័យ ពិសេសគ្រួសារលោកស្រីមានគំនិត និងគោលបំណងដូចគ្នានិងចេះជួយគ្នាទៅវិញទៅមក រីឯកិច្ចការពាក់ព័ន្ធនឹងការចែករំលែកបទពិសោធន៍ លោកស្រីបានឱ្យដឹងថា គាត់តែងផ្តល់ឱកាសសម្រាប់អ្នកចង់ស្វែងយល់ រៀនសូត្រពីការចិញ្ចឹមមាន់មិនថាមកពីទីឆ្ងាយឬជិតយ៉ាងទេ និងជាពិសេសចំពោះកសិករដែលមកទិញកូនមាន់ ត្រូវបានលោកស្រីណែនាំនិងធ្វើបង្ហាញពីរបៀបចិញ្ចឹម និងថែទាំមាន់ ដោយផ្ទាល់តែម្តង៕

### សម្រាប់ព័ត៌មានលម្អិតសូមទំនាក់ទំនងមកៈ

- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តត្បូងឃ្មុំ លោក **ហេង ពិសិដ្ឋ** ទូរស័ព្ទលេខ ០៩៧ ៧៥៨១៩៥២
- លោកស្រី **ពុត សុជា** កសិករជ័យលាភី លើការចិញ្ចឹមមាន់ភ្ញាស់កូន ទូរស័ព្ទលេខៈ ០៨៨ ៤៣១១៣៩៩<br>០៩៧ ៧៨៨៧ ៤៣០<br>០៩៦ ៣៣ ៩៩ ៤៧៧